00629852

F14/2

**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ: សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: បារាំង(បកប្រែភាសាខ្មែរ)

កាលបរិច្ឆេទឯកសារ: ០៣ ធ្នូ ២០១០

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 03 / 12 / 2010
ម៉ោង (Time/Heure): 11:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សារណាឆ្លើយតបរបស់ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក្រុម៣ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ភាគីការពារខុច ជំទាស់នឹងសាលក្រមដែលបានចេញនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០។**

---

| **ដាក់ដោយ៖** | **ដាក់ជូន៖** |
|---|---|
| **សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី** | **អង្គជំនុំជម្រះតុលាការកំពូល៖** |
| មេធាវី គីម ម៉េងឃី | ចៅក្រម គង់ ស្រីម |
| មេធាវី ម៉ុច សុវណ្ណារី | ចៅក្រម សោម សិរិវឌ្ឍ |
| មេធាវី Martine JACQUIN | ចៅក្រម ស៊ិន រិទ្ធ |
| មេធាវី Annie DELAHAIE | ចៅក្រម **MOTOO NOGUCHI** |
| មេធាវី Philippe CANONNE | ចៅក្រម **Agnieska KLONOWIECKA-MILART** |

សារណាឆ្លើយតបរបស់ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក្រុម៣ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ភាគីការពារខុច ជំទាស់នឹងសាលក្រមដែលបានចេញនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០។

00629853

F14/2

មេធាវី Elisabeth TRUSSES NAPROUS ចៅក្រម **Chandra Nihal-Jayasinghe**

មេធាវី Christine MARTINEAU ចៅក្រម យ៉ា ណារីន

**ចំលងជូន៖**

**ជនជាប់ចោទ៖**

កាំង ហ្គេកអ៊ាវ ហៅ «ឌុច»

**មេធាវីជនជាប់ចោទ៖**

មេធាវី ការ សាវុត្ថ

**សហព្រះរាជអាជ្ញា៖**

ជា លាង

Andrew CAYLEY

យ៉េត ចរិយា

William SMITH

**សហមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណី៖**

មេធាវី Karim KHAN

មេធាវី ទី ស្រ៊ីនណា

មេធាវី Alain WERNER

មេធាវី យ៉ុង ផានិត

មេធាវី នី ចាន់ឌី

មេធាវី ឡោ ជុនធី

មេធាវី គង់ ពិសី

មេធាវី ហុង គឹមសួន

មេធាវី Silke STUDZINSKY

F14/2

## I. រំលឹកអង្គហេតុ និង នីតិវិធី

1- នៅថ្ងៃទី២៦ កក្កដា ២០១០អង្គជំនុំជម្រះសាលាដំបូងនៃអ.វ.ត.ក.បានប្រកាសថា កាំង ហ្កេក អ៊ាវ ជាពិរុទ្ធជននៃឧក្រិដ្ឋកម្មរំលោភធ្ងន់ធ្ងរលើកិច្ចព្រមព្រៀងហ្សឺណែវ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិព្រមទាំងបានផ្តន្ទាទោសដាក់ពន្ធនាគារ ៣៥ឆ្នាំ ដោយដកចេញចំនួន ៥ឆ្នាំពីការឃុំខ្លួនដោយបំពានលើពិរុទ្ធជនរូបនេះ។

2- នៅថ្ងៃទី០៥ តុលា ២០១០ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងនូវបណ្តឹងឧទ្ធរណ៍ដើម្បីជំទាស់នឹងសាលក្រមដែលបានប្រកាសថាមិនទទួលយកដោយគ្មានមូលដ្ឋាននូវការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនដែលតំណាងដោយក្រុមមេធាវីខាងលើ និង លើបញ្ហាសំណង។

3- នៅថ្ងៃទី១៣ តុលា ២០១០ សហព្រះរាជអាជ្ញាបានដាក់នូវបណ្តឹងសារទុក្ខ របស់ខ្លួនជំទាស់នឹងសាលក្រមដោយស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលធ្វើការកែប្រែឡើងវិញចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និង ផ្តន្ទាទោស « ឌុច » ឲ្យជាប់ពន្ធគារអស់មួយជីវិត។

4- នៅថ្ងៃទី១៨ តុលា ២០១០ បន្ទាប់ពីមានការស្នើសុំពន្យាររយៈពេលនៃការធ្វើបណ្តឹងឧទ្ធរណ៍ដោយមេធាវីភាគីការពារអង្គជំនុំជម្រះតុលាការកំពូលបានយល់ព្រមបន្ថែមរយៈ៣០ថ្ងៃទៀតសម្រាប់ភាគីការពារដើម្បីដាក់នូវបណ្តឹងសារទុក្ខរបស់ខ្លួន។

5- នៅថ្ងៃទី២០ តុលា ២០១០ ក្រឡាបញ្ជីអមអង្គជំនុំជម្រះតុលាកំពូលបានផ្ញើរ សំបុត្រមួយច្បាប់ដើម្បីដឹងថាតើក្រុមពាធ្វើការសង្កេតទាក់ទងនឹងបណ្តឹងសារទុក្ខខុសគ្នាទាំងនេះដែរឬទេ ហើយបើសិនជាយល់ព្រម តើភាសាណាមួយដែលប្រើជាផ្លូវការ។

6- តាមរយៈសំបុត្រនៅថ្ងៃទី២៧ តុលា ២០១០ សហមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីបានឲ្យដឹងអំពីឆន្ទៈរបស់ខ្លួនក្នុងការដាក់នូវការសង្កេតដែលទាក់ទងនឹងបណ្តឹងសារទុក្ខទាំងនេះ ដោយធ្វើការតាក់តែងឡើងជាភាសាបារាំង និង ភាសាខ្មែរ។

សារណាឆ្លើយតបរបស់ក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក្រុម៣ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ភាគីការពារឌុចជំទាស់នឹងសាលក្រមដែលបានចេញនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០។

F114/2

7- សហមេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ បានដាក់សារណារបស់ខ្លួនដោយអនុលោមទៅតាមវិធានផ្ទៃក្នុង និង សេចក្តីណែនាំអនុវត្តផ្សេងៗ។

8- នៅថ្ងៃទី១៨ វិច្ឆិកា ២០១០ សហមេធាវីរបស់ភាគីការពារបានដាក់នូវបណ្តឹងឧទ្ធរណ៍របស់ខ្លួនជំទាស់នឹងសាលក្រមដែលបានចេញកាលពីថ្ងៃទី២៦ កក្កដា ២០១០ និង បានស្នើសុំ :

« ដោយនិយាយថាសាលក្រមដែលបានចេញគឺគ្មានមូលដ្ឋានស្របច្បាប់ និង ស្នើសុំធ្វើការដោះលែងកូនក្តីរបស់ខ្លួនឱ្យមានសេរីភាព និងចាត់ទុកថារយៈពេលប៉ុន្មានឆ្នាំដែលបានធ្វើការឃុំខ្លួន កាំង ហ្កេកអ៊ាវ ដូចជាវិធានការការពារ និង ទុកដូចជាសាក្សីដ៏សំខាន់ដើម្បីប្រឆាំងនឹងអ្នកដឹកនាំខ្ពស់នៃរបបកម្ពុជាប្រជាធិតេយ្យ សម្រាប់បទឧក្រិដ្ឋដែលបានកើតឡើងនៃមន្ទីរស២១»។

II. **កិច្ចពិភាក្សា**

9- ជនជាប់ចោទបានគាំទ្រនៅក្នុងសារណារបស់ខ្លួនថា អង្គជំនុំជម្រះមានការភន្តច្រឡំដែលវាយតម្លៃរូបគាត់ថាជាអ្នកទទួលខុសត្រូវដ៏សំខាន់នៃបទឧក្រិដ្ឋដែលបានកើតឡើងនៅមន្ទីរស២១ ដែលអង្គជំនុំជម្រះមិនអាចចេញសេចក្តីសម្រេចបែបនេះដោយយោងទៅតាមមាត្រា១ស្តីពីអ.វ.ត.ក. និងមាត្រា៨៧ នៃវិធានផ្ទៃក្នុង។

10- សម្រាប់ជនជាប់ចោទ អង្គជំនុំជម្រះមិនមានសមត្ថកិច្ចក្នុងការចេញសេចក្តីសម្រេច លើរូបគាត់ឡើយ។

11- ជនជាប់ចោទបានគាំទ្រនៅក្នុងសារណារបស់ខ្លួនថា អង្គជំនុំជម្រះមានការភន្តច្រឡំទៅលើបុគ្គលដោយធ្វើការសន្និដ្ឋានថាជនជាប់ចោទគឺត្រូវចាត់ចូលទៅក្នុងប្រភេទអ្នកទទួលខុសត្រូវសំខាន់នៃបទឧក្រិដ្ឋធ្ងន់ធ្ងរដែលបានកើតឡើងក្នុងកំឡុងថ្ងៃទី១៧ មេសា ១៩៧៥ និង ថ្ងៃទី០៦ មករា ១៩៧៩ និងជាពិសេសគឺកើតឡើងនៅមន្ទីរស២១។

12- ផ្ទុយពីការចោទប្រកាន់ចំពោះជនជាប់ចោទ តាមពិតជនជាប់ចោទមិនមែនគ្រាន់ តែជាអ្នកប្រព្រឹត្តធម្មតា ដែលគ្មានអំនាច និង គ្មានលទ្ធភាពក្នុងការផ្តល់នូវយោបល់នោះទេ។

F14/2

13- កាំង ហ្កេកអ៊ាវ ហៅ ឌុចត្រូវបានតែងតាំងជាអនុប្រធាន និង បន្ទាប់មកក្លាយជាប្រធាននៃមន្ទីរសន្តិសុខ ស២១ដោយសមាជិកអចិន្ត្រៃយ៍នៃគណៈមជ្ឈិមក្នុងជំនាន់នោះព្រមទាំងបទពិសោធន៍របស់គាត់ក្នុងការគ្រប់គ្រងមន្ទីរឃុំឃាំង ម១៣ ដែលជាកន្លែងដែលធ្វើឱ្យគាត់ ទទួលបាននូវទំនុកចិត្ត បង្ហាញអំពីចិត្តភក្តីរបស់គាត់នៅក្នុងរបបនេះ និង ជាពិសេសទទួលបានគុណភាពជា «អ្នកសួរចម្លើយដ៏ល្អបំផុត» ។ ការតែងតាំងរបស់គាត់ដោយ សុន សេន មិនអាចធ្វើឱ្យគាត់ ធ្វើមិនដឹង មិនលឺចំពោះការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គលសម្រាប់បទឧក្រិដ្ឋដែលបានកើតឡើងនៅស២១ឡើយ។

14- ជនជាប់ចោទដូចដែលគាត់ត្រូវបានចោទប្រកាន់ទាំងក្នុងដំណាក់កាលស៊ើបអង្កេត និងទាំងសវនាការគឺគាត់បានដឹកនាំយ៉ាងសកម្មនៅមន្ទីរស២១។ ជនជាប់ចោទមានតួនាទីជាអ្នកត្រួតពិនិត្យ[1] ចូលរួមក្នុងការសួរចម្លើយ[2] ចារសេចក្តីពន្យល់ចំពោះពាក្យសម្បថ ផ្តល់នូវផ្នែកមួយក្នុងការតាមដានស្រាវជ្រាវរកអ្នកដែលក្បត់ថ្មី[3] គ្រប់គ្រងបុគ្គលិកនៅក្នុងមន្ទីរដែលស្ថិតនៅក្រោមបញ្ជារបស់គាត់ បង្កើតនូវការសួរចម្លើយ និង ការធ្វើទារុណកម្ម[4]។

15- ជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅឌុចមានអំនាចលើសលុបក្នុងការត្រួតពិនិត្យចំពោះការប្រព្រឹត្តអ្នកក្រោមបង្គាប់ និង អ្នកដែលជាប់ឃុំឃាំងនៅមន្ទីរស២១។

16- ជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅឌុច បានរៀបចំជាធាកជាមុន និង ចូលរួមដោយដឹងពីមូលហេតុ ទោះដោយផ្ទាល់ និង មិនផ្ទាល់អំពីការបោសសំអាតមនុស្សចំនួន ១២២៧៣នាក់។ គាត់បានចូលរួមយ៉ាងសកម្មចំពោះនយោបាយ និង វិធីនៃការធ្វើការវកម្ម។ ហេតុការដែលមានភាពសាហាវ បំផុតដែលបានប្រព្រឹត្តនៅមន្ទីរស២១ស្ថិតនៅក្រោម កូនចៅរបស់គាត់ជាអ្នក

[1] អង្គជំនុំជម្រះសាលាដំបូងអ.វ.ត.ក. សេចក្តីសម្រេចថ្ងៃទី២៦ កក្កដា ២០១០ កថា ១២៨

[2] អង្គជំនុំជម្រះសាលាដំបូងអ.វ.ត.ក. សេចក្តីសម្រេចថ្ងៃទី២៦ កក្កដា ២០១០ កថា ១៧៦

[3] អង្គជំនុំជម្រះសាលាដំបូងអ.វ.ត.ក. សេចក្តីសម្រេចថ្ងៃទី២៦ កក្កដា ២០១០ កថា ១៧៧ និង ១៧៨

[4] អង្គជំនុំជម្រះសាលាដំបូងអ.វ.ត.ក. សេចក្តីសម្រេចថ្ងៃទី២៦ កក្កដា ២០១០ កថា ១៦៣

00629857

F14/2

ប្រព្រឹត្តបង្កើតបានជា បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និង ឧក្រិដ្ឋកម្មរំលោភធ្ងន់ធ្ងរលើកិច្ចព្រមព្រៀងហ្សឺណែវ ។

17- ជាការខុសមួយដែលជនជាប់ចោទបានគាំទ្រថា អង្គជំនុំជម្រះមានការភន្តច្រឡំដោយសន្និដ្ឋានថារូបគាត់ជាអ្នកទទួលខុសត្រូវដ៏សំខាន់ចំពោះបទឧក្រិដ្ឋដ៏សាហាវយង់ឃ្នងដែលបានកើតឡើងក្នុងកំឡុងថ្ងៃទី ១៧ មេសា ១៩៧៥ និង ថ្ងៃទី ០៦ មករា ១៩៧៩ នៅមន្ទីរស២១។

18- អង្គជំនុំជម្រះបានគាំទ្រចំពោះការវាយតម្លៃដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតបន្ទាប់ ពីបានស៊ើបអង្កេតលើសំនុំរឿងរួមមក។ ជនជាប់ចោទមិនអាចសន្និដ្ឋានថា ការវាយតម្លៃនេះ មិនត្រូវបានធ្វើដោយឈរលើមូលដ្ឋានច្បាស់លាស់ស្របច្បាប់ដោយសំអាងថា ដីកាសន្និដ្ឋានបញ្ជូនរឿង ឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាដែលបានចាត់ទុក ជនជាប់ចោទកាំង ហ្គេកអ៊ាវ ហៅឌុច គឺជាបុគ្គលម្នាក់ដែលស្ថិតនៅក្នុងចំនោមអ្នកដឹកនាំខ្ពស់បំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យ។ សហចៅក្រមស៊ើបអង្កេត មិនត្រឹមតែធ្វើការស៊ើបអង្កេតចំពោះអង្គហេតុ និង បទល្មើសដែលចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរប៉ុណ្ណោះនោះទេ ប៉ុន្តែគាត់ក៏មានអំនាចក្នុងការវាយតម្លៃផ្សេងពីនោះដែរ។អំនះអំណាងដែលលើកឡើងដោយជនជាប់ចោទមិនអាចត្រូវទទួលយកនោះទេ។

19- ផ្ទុយពីសម្តីរបស់ជនជាប់ចោទ[5] គឺគ្មានការភ័ន្តច្រឡំទាល់តែសោះចំពោះជាភាសាបារាំងទាក់ទិនទៅនឹងឃ្លា « អាចចាត់ទុកថាចូលទៅក្នុងផ្នែកដែលបានលើកឡើងដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាដំណោះស្រាយ និង អង្គជំនុំជម្រះនៅក្នុងសាលក្រម »។ ឃ្លាមួយនេះមិនអាចត្រូវបានបកប្រែក្នុងលក្ខណៈដែលសម្តែងនូវភាពសង្ស័យនោះទេ តាមពិតឃ្លានេះគឺមានន័យថាជាការអះអាងគាំទ្រ។

---

[5] សារណានៃបណ្តឹងឧទ្ធរណ៍របស់ភាគីការពារប្រឆាំងនឹងសាលក្រមដែលចេញកាលពីថ្ងៃទី២៦ កក្កដា ២០១០ ថ្ងៃទី១៨ វិច្ឆិកា ២០១០ កថា ១៦

00629858

F14/2

20- ជាការគួសបញ្ជាក់ជាច្រើនដងរួចមកហើយថា ជនជាប់ចោទតាមរយៈសារណាររបស់ខ្លួនបាន បកប្រែក្នុងលក្ខណៈមួយដែលមានការភ័ន្តច្រឡំចំពោះផ្នែកខ្លះនៃសាលក្រម។ កថាខណ្ឌ៩៩នៃ សាលក្រមមិនបានចែងទាល់តែសោះអំពីការស្នើរបស់លោកស្រីចៅក្រម Cartwright ដូចដែល បានចែងនៅក្នុងសារណាររបស់ខ្លួនឡើយ[6]។ រាល់សម្មតិកម្មទាំងអស់ តាមរយៈ កថាខណ្ឌ៩៩នេះ បានរំលឹកថា « ក្នុងចំនោមនយោបាយទាំងអស់នៃគណៈបក្សកុំមុយនីសកម្ពុជាអ្វីដែលគួរឲ្យកត់ សម្គាល់បំផុតនោះគឺ «ការកំទេច» សត្រូវ នយោបាយនេះបានអនុវត្តជាដំបូងនៅ ម១៣ » នយោបាយនេះគឺបានគាំទ្រ រកឃើញ និង អនុវត្តដោយជនជាប់ចោទកាំង ហ្កេកអ៊ាវ ហៅឌុចនៅម១៣។ លើសពីនេះទៀត វាប្រាកដណាស់ថាគាត់គឺអាចផ្តល់ឥទ្ធិពលក្នុងការ ស្រាវជ្រាវរក «សត្រូវ» ផងដែរ។ កថាខណ្ឌ៩៩នេះមិនបានបង្ហាញដោយដាច់ខាតថា «ឌុច» មិនមែនជាអ្នកទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលបានកើតឡើង ដូចដែលបានលើកឡើងនៅក្នុង សារណាររបស់គាត់ឡើយ។

21- លើសពីនេះទៀត ជនជាប់ចោទដើម្បីសន្និដ្ឋានអំពីអសមត្ថកិច្ចរបស់អង្គជំនុំជម្រះ អាងលើ ទស្សនៈដែលខុសពីមតិភាគច្រើនរបស់ចៅក្រម Lavergne «អង្គហេតុដែលអាចទទួលយកបាន» ។ រីឯការអានទៅលើមតិនេះ គ្មានអ្វីដែលខុសប្លែកលេចឡើងទាល់តែសោះ នេះគ្រាន់តែជាខ្វែង គំនិតគ្នាលើក្រមខ័ណ្ឌគតិយុត្តិទាក់ទងនឹងការកំណត់ទោស និង មិនមែនពាក់ព័ន្ធនឹងសមត្ថកិច្ច របស់អង្គជំនុំជម្រះក្នុងការកាត់ក្តី ជនជាប់ចោទកាំង ហ្កេកអ៊ាវ ហៅឌុច។

22- អសមត្ថកិច្ចរបស់អង្គជំនុំជម្រះមិនត្រូវលើកឡើងផងដែរក្នុងលក្ខណៈជាទម្រង់ និង ត្រឹមត្រូវ ដោយជនជាប់ចោទនោះទេ។

23- តាមរយៈការអនុវត្តនីតិកម្ពុជា វិធាន នីតិទម្លាប់អន្តរជាតិ និង អនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាបានចូលរួម ហើយបញ្ជាក់ថាអង្គជំនុំជម្រះបានសន្និដ្ឋានត្រឹមត្រូវ និង បាន

[6] សារណានៃបណ្តឹងឧទ្ធរណ៍របស់ភាគីការពារប្រឆាំងនឹងសាលក្រមដែលចេញកាលពីថ្ងៃទី២៦ កក្កដា ២០១០ ថ្ងៃទី១៨ វិច្ឆិកា ២០១០ កថា ៣០

F1L/2

ចាត់ទុករាល់អង្គហេតុដែលបានកើតឡើងប្រឆាំងជាមួយ « ឌុច » ដើម្បីចូលទៅក្នុងមាត៌ានៃការផ្តន្ទាទោស។

## III. សេចក្តីសន្និដ្ឋាន

24- សហមេធាវីនៃភាគីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ ស្នើសុំឱ្យធ្វើការច្រានចោលនូវអំណះអំណាងដែលលើកឡើងដើម្បីគាំទ្រសារណាដែលបានដាក់ដោយសហមេធាវីភាគីការពាររបស់ ជនជាប់ចោទកាំង ហ្កេកអ៊ាវ ហៅឌុចថាមិនបានឈរលើមូលដ្ឋានត្រឹមត្រូវ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០៣ ធ្នូ ២០១០

ដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣

មេធាវី ម៉ុច សុវណ្ណារី

**Me Martine JACQUIN**
**Chef de projet ASF-France**

មេធាវី Martine JACQUIN

មេធាវី Philippe CANONNE

មេធាវី Christine MARTINEAU

មេធាវី Fabienne TRUSSES-NAPROUS

មេធាវី Annie DELAHAIE

មេធាវី Elisabeth RABESANDRATANA